ADB

**ASIAN DEVELOPMENT BANK**
6 ADB Avenue, Mandaluyong City
1550 Metro Manila, Philippines
Tel +63 2 632 4444
Fax +63 2 636 2444

www.adb.org

## សេចក្តីប្រកាសព័ត៌មាន

# ប្រទេសមហាអនុតំបន់ទន្លេមេគង្គខិតខំបន្តជម្រុញការវិនិយោគទៅលើធនធានធម្មជាតិ

**NAY PYI TAW, MYANMAR (ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥) –** បណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ (GMS) បានប្តេជ្ញាបង្កើនកិច្ចខិតខំទ្វេដងជាថ្មីម្តងទៀតដើម្បីការពារ និង លើកកម្ពស់ធនធានធម្មជាតិរបស់ពួកគេ ដែលរួមមាន ព្រៃឈើ ដីកសិកម្ម ដីសើម និង ប្រភពទឹក ដើម្បីធានាថា ធនធានធម្មជាតិទាំងនោះរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ខណៈពេលដែលមានការព្រួយបារម្ភថាការខកខានមិនបានចាត់វិធានការការពារ អាចបង្កឱ្យមានការគំរាមកំហែងចំពោះកំណើនសេដ្ឋកិច្ចនាពេលអនាគតរបស់អនុតំបន់នេះ។

ថ្នាក់ដឹកនាំផ្នែកបរិស្ថានមកពីបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ នៅឯកិច្ចប្រជុំរដ្ឋមន្ត្រីបរិស្ថានលើកទី៤ នៃអនុតំបន់នេះ បានអំពាវនាវឱ្យមានភាពជាដៃគូកាន់តែរឹងមាំ ដើម្បីលើកកម្ពស់ការយល់ដឹង និងបង្កើតព័ត៌មានអំពីធនធានធម្មជាតិ ក្នុងគោលបំណងសម្របសម្រួល និងផ្តល់ហិរញ្ញប្បទានសម្រាប់គំនិតផ្តួចផ្តើមដើម្បីការពារធនធានធម្មជាតិទាំងនោះ ព្រមទាំងដើម្បីអភិវឌ្ឍន៍វិធីសាស្ត្រផ្សេងៗក្នុងការធានាថា រាល់ការពិចារណាផ្សេងៗអំពីនិរន្តរភាព នឹងផ្តល់ព័ត៌មានសម្រាប់ការរៀបចំគោលនយោបាយ ផែនការ និង សេចក្តីសម្រេចចិត្តក្នុងការវិនិយោគ។

សេចក្តីថ្លែងការណ៍រួមមួយពីរដ្ឋមន្ត្រីបរិស្ថាននៃប្រទេសកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសភូមា សាធារណរដ្ឋប្រជាមានិតចិន ប្រទេសថៃ និងប្រទេសវៀតណាម បានថ្លែងថា "មូលធន/ធនធានធម្មជាតិគឺជាបេះដូងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច"។ "វិបុលភាពនៅពេលអនាគតរបស់មហាអនុតំបន់ទន្លេមេគង្គ គឺអាស្រ័យលើការវិនិយោគទាន់ពេលវេលា និង ប្រកបដោយប្រសិទ្ធភាព ដើម្បីការពារ និងលើកកម្ពស់មូលធន/ធនធានធម្មជាតិទាំងនេះ"។

មូលធនធម្មជាតិគឺជាឃ្លាំងនៃទ្រព្យសម្បត្តិធម្មជាតិដែលបង្កើតឱ្យមាននូវលំហូរនៃសេវាប្រព័ន្ធអេកូឡូស៊ីដូចជា អាហារ ទឹក ថាមពល និងការទប់ស្កាត់ជម្ងឺ ដែលសុទ្ធសឹងតែមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសុខុមាលភាពមនុស្ស។ វាមានសារៈសំខាន់ជាពិសេសសម្រាប់មហាអនុតំបន់ទន្លេមេគង្គ ដែលពឹងផ្អែកខ្លាំងលើដីកសិកម្ម ព្រៃឈើ ដីសើម ព្រៃកោងកាង និងសេវាប្រព័ន្ធអេកូឡូស៊ីដែលពាក់ព័ន្ធផ្សេងៗទៀតដើម្បីបង្កើតកាលានុវត្តភាពសេដ្ឋកិច្ច។ ទ្រព្យមូលធនធម្មជាតិមានចំនួនចន្លោះពី ២០% ទៅ ៥៥% នៃទ្រព្យសម្បត្តិក្នុងបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ ដែលផ្តល់ការការពារដ៏សំខាន់សម្រាប់វិបុលភាពនៅពេលអនាគត។

មូលធនធម្មជាតិដើរតួនាទីដ៏សំខាន់នៅក្នុងជីវិតរស់នៅរបស់ប្រជាជនក្រីក្រក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលប្រជាជនជនបទចំនួន ៦០លាននាក់ ពឹងអាស្រ័យទៅលើបរិស្ថានរបស់ពួកគេ ដើម្បីទទួលបាន អាហារ ទឹក ថាមពល និងប្រាក់ចំណូល។ បើទោះជាដូច្នេះក្តី ការធ្វើអាជីវកម្មលើធនធានធម្មជាតិហួសប្រមាណ ភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិផ្សេងៗដែលកំពុងមានការកើនឡើង កំពុងតែគំរាមកំហែងដល់ជីវភាពរស់នៅរបស់សហគមន៍ទាំងនេះ។ លើសពីនេះទៀត ភាពវិចវិលបរិស្ថានបង្កឱ្យមានហានិភ័យចំពោះការរក្សាកំណើនសេដ្ឋកិច្ចរយៈពេលវែងនៅក្នុងអនុតំបន់ ព្រមទាំងអាចបង្កឱ្យមានចំណាយចំនួន ៥៥ពាន់លានដុល្លា ក្នុងរយៈពេល២៥ឆ្នាំក្រោយ ប្រសិនបើគ្មានការត្រួតពិនិត្យឱ្យបានត្រឹមត្រូវ។

នៅក្នុងចំណាប់អារម្មណ៍ស្វាគមន៍ឯកិច្ចប្រជុំ លោក James Nugent អគ្គនាយកនៃនាយកដ្ឋានអាស៊ីអាគ្នេយ៍ របស់ធនាគារអភិវឌ្ឍន៍អាស៊ី បានមានប្រសាសន៍ថា "បញ្ហាប្រឈមសំខាន់មួយដែលមហាអនុតំបន់ទន្លេមេគង្គកំពុងជួបប្រទះក្នុងទសវត្សរ៍ខាងមុខនេះ គឺការបំពេញតម្រូវការដែលកំពុងតែមានការកើនឡើង សម្រាប់ អាហារ ថាមពល ទឹក និងធនធានធម្មជាតិផ្សេងៗទៀត ហើយស្របពេលជាមួយគ្នានេះ ត្រូវធានាថាធនធានទាំងនេះ មានរួចជាស្រេច សម្រាប់មនុស្សជំនាន់ក្រោយៗ"។

លោក Nugent បានអំពាវនាវឱ្យមានការរួមវិភាគទានលើផ្នែកសង្គម និងសេដ្ឋកិច្ច សម្រាប់ធនធានធម្មជាតិ ដើម្បីធ្វើការប៉ាន់ប្រមាណ និងវាយតម្លៃឱ្យបានត្រឹមត្រូវក្នុងការផ្តល់ទស្សនៈទានសំខាន់ៗដល់អ្នកបង្កើតគោលនយោបាយអំពីតុល្យភាពដែលពាក់ព័ន្ធនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីការអភិវឌ្ឍន៍។ លោកបានមានប្រសាសន៍ថា ការពិចារណាទៅលើការអភិវឌ្ឍន៍សម្រាប់ទាំងអស់គ្នា និងនិរន្តរភាព គួរតែអាចផ្តល់នូវការរៀបចំ និងការប្រើប្រាស់ទឹកប្រាក់ចំនួនជាង ៣០ពាន់លានដុល្លា សម្រាប់គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចអាទិភាពខ្ពស់ៗ ដែលផែនការអនុវត្តក្របខ័ណ្ឌវិនិយោគតំបន់ បានបង្ហាញនៅឯកិច្ចប្រជុំកំពូលលើកទី៥របស់ថ្នាក់ដឹកនាំនៃមហាអនុតំបន់ទន្លេមេគង្គ កាលពីខែធ្នូកន្លងទៅនេះ។

ដោយមានមូលដ្ឋាននៅក្នុងទីក្រុងម៉ានីល ធនាគារអភិវឌ្ឍន៍អាស៊ីប្តេជ្ញាកាត់បន្ថយភាពក្រីក្រនៅអាស៊ី និងប៉ាស៊ីហ្វិក តាមរយៈកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា កំណើនសេដ្ឋកិច្ចដែលមាននិរន្តរភាពចំពោះបរិស្ថាន និងសមាហរណកម្មតំបន់។ បង្កើតឡើងក្នុងឆ្នាំ១៩៦៦ ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាកម្មសិទ្ធិរបស់សមាជិកចំនួន ៦៧ ក្នុងនោះ មានសមាជិកចំនួន៤៨ គឺជាប្រទេសនៅក្នុងតំបន់។

Media Inquiries:
**John Larkin**
**External Relations Specialist**
**Tel: (632) 632-6618**
**E-mail: jlarkin@adb.org**

Connect with us on Twitter @ADB_HQ